**ខ្លឹមសារសង្ខេប ចម្លើយតបរបស់មេធាវីការពារក្តី E72/2 ទៅនឹងសំណើសុំរបស់ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី E72**

**ពាក្យគន្លឹះ៖** ដើមបណ្តឹងរដ្ឋប្បវេណី, សិទ្ធិដាក់សារណា។

**អង្គហេតុនិងការសម្រេច៖** ដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើដល់អង្គជំនុំជម្រះសាលា ដំបូង TC ដើម្បីដាក់សារណាស្តីពីទោសទណ្ឌលើពិរុទ្ធជន។ ដើម្បីសម្រេច TC បានសុំយោបល់ភាគីពាក់ព័ន្ធរួមមានមេធាវីការពារជនជាប់ចោទផងដែរ។

ក្នុងឯកសារឆ្លើយតប មេធាវីអះអាងថា គោលការណ៍នៃស៊ីវិលឡ (civil law principle) មានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការដាក់សារណាស្តីពីទោសទណ្ឌក្នុងអំឡុងពេលសវនាការ។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណា...វាទំនងជាហេតុនេះហើយ ដែលក្រុមមេធាវីដើមបណ្តឹងដទៃទៀតមិនចូលរួមធ្វើសំណើ (កថាទី៥)។ វិធានផ្ទៃក្នុងនៃ **អវតក** ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងអនុញ្ញាតនូវសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីលើទោសទណ្ឌ។ ជាចុងក្រោយ សាក្សីពីររូប ត្រូវបានស្នើកោះហៅដោយដើមបណ្តឹងរដ្ឋប្បវេណីរួចទៅហើយ ដែលអាចជួយ TC ក្នុងការកំណត់ទោសទណ្ឌដែលនឹងត្រូវដាក់។

សូមមើលបន្ថែមខ្លឹមសារសង្ខេបសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី E72 និងចម្លើយតបរបស់សហព្រះរាជអាជ្ញា E72/1។

**Defence Response to Groups 1 and 2-Civil Parties' Co-Laywers Joint Request for A Ruling on the Standing of Civil Party Lawyers to Make Submissions on Sentencing, ECCC, E72/2 (18 August 2009)**

**Key Issues**: Civil Parties, right to make submissions.

**Facts/Arguments**: Defence counsel asserted that under the civil law principle, only the Prosecutor has the right to make submissions on sentencing during the trial. The French Criminal Procedure Code does not permit Civil Parties to make such submissions, which may be why other Civil Party groups did not join the request. They claimed that neither the ECCC IRs nor the Cambodian Criminal Procedure Code allows Civil Parties to make submissions on sentencing. Finally, the Defence noted that two witnesses were proposed by the Civil Parties to be called, which could assist the TC in determining the sentence to be imposed.